អមរា

AMARA

បោះពុម្ពផ្សាយបន្ថែមដោយ

អង្គការ អមរា

ឧបត្ថម្ភមូលនិធិដោយ

អង្គការហ្វ័រុមស៊ីដ FORUM SYD

និង

ជំនួយព្រះវិហារដាណឺម៉ាក DANCHURCHAID

Published by AMARA
Funded by FORUM SYD
and
DANCHURCHAID

110

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

# ការបង្ក្រាបអំពើចាប់ពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស

# Law On The Suppression Of Kidnapping, Trafficking and Exploitation of Human Persons

1996

# ព្រះរាជក្រម

ជស/រកម/០២ ៩៦/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

*********

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.04 ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្សដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**********

**រដ្ឋសភា**

លេខ : ២០ រស

ភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៦

**សូមទូលថ្វាយនិងជម្រាប**

**សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២**

សូមព្រះមេត្តានិងមេត្តាជ្រាប ។

**កម្មវត្ថុ** : ការអនុម័តច្បាប់ស្តីពី **ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស**

**យោង** : សំណើលេខ ៥៣ លស ចុះថ្ងៃទី១៩ សីហា ១៩៩៥ របស់រាជរដ្ឋាភិបាល

តាមសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទូលព្រះបង្គំ ខ្ញុំមានកិត្តិយសសូមទូលថ្វាយនិងជំរាបសម្តេច សូមព្រះ

មេធ្លានិងមេធ្លាជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តយល់ព្រមចំនួន ៨០ សម្លេង លើច្បាប់ខាងលើនេះកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៥ នីតិកាលទី១ ។

ទូលព្រះបង្គំ ខ្ញុំ សូមថ្វាយនិងជូនភ្ជាប់មកជាមួយនូវច្បាប់ខាងលើនេះ ដើម្បីព្រះមេធ្លានិងមេធ្លាចាត់ចែងការងារតាមការគួរ ។

ជា ស៊ីម

ចម្លងជូន :

- គណៈកម្មាធិការអចិន្ត្រៃយ៍
  "ដើម្បីជូនជ្រាប"



មធ្យោបាយដឹកជញ្ជូន សម្ភារៈនិងទ្រព្យសម្បត្តិប្រើប្រាស់ ក្នុងពេលប្រព្រឹត្តបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៣

## អំពីសញ្ចារកម្ម

### មាត្រា ៥.-

នឹងត្រូវចាត់ទុកជាសញ្ចារិកឬសញ្ចារិកាឬជនមេពេស្យា ជនណា :

១-ដែលទំនុកបំរុងឬការពារជនណាម្នាក់ឬច្រើននាក់ ទោះបីតាមមធ្យោបាយណាក៏ដោយ ហើយដោយបានដឹងជាមុននូវអំពើពេស្យាចាររបស់ជននោះឬក៏ទាក់ភ្ញៀវឱ្យជននោះ ក្នុងគោលដៅពេស្យាចារ ឬ

២-ដែលចែកភាគផល ដែលបានមកពីអំពើពេស្យាចារជាប្រក្រតី ទោះជាក្នុងទ្រង់ទ្រាយណាក៏ដោយណា ឬ

៣-ដែលយកស្ត្រីឬបុរស ទោះបីតាមមធ្យោបាយណាក៏ដោយ ទៅបង្ហាត់បង្រៀនបញ្ចុះបញ្ចូលឱ្យធ្វើជាស្ត្រីឬបុរសពេស្យា ឬ

៤-ដែលធ្វើជាអ្នកកណ្តាល ទោះបីតាមរូបភាពណាក៏ដោយ បង្កើតឱ្យមានទំនាក់ទំនងរវាងបុរសពេស្យាឬស្ត្រីពេស្យា ជាមួយនឹងមេបនពេស្យាចារឬជាមួយអ្នកផ្តល់កម្រៃលើពេស្យាចារអ្នកដទៃ ឬ

៥-ដែលឱ្យបុរសឬស្ត្រី នៅក្នុងផ្ទះរបស់ខ្លួនឬកន្លែងណាមួយ ក្នុងគោលដៅឱ្យជនទាំងនោះធ្វើពេស្យាចារយកប្រាក់ឱ្យខ្លួន ។

មាត្រា ៥.-

សញ្ចារិកឬសញ្ចារិកាឬជនជាមេពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ក្នុងករណីមិនរាងចាលត្រូវយកទ្វេគុណនៃទោសបករអនុវត្ត ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីសញ្ចារកម្ម :

១-ប្រព្រឹត្តបទល្មើសលើអនីតិជនអាយុក្រោម ១៥ឆ្នាំ ឬ

២-ប្រព្រឹត្តបទល្មើសដោយបង្ខិតបង្ខំហិង្សា ឬដោយមានការគំរាមកំហែងឬដោយ មានអាវុធ ឬ

៣-ប្រព្រឹត្តដោយជា ស្វាមី ភរិយាឬសង្សារ ឬឪពុកឬម្តាយឬអាណាព្យាបាលដែលបង្ខំបុរសឬស្ត្រីឱ្យធ្វើពេស្យាចារ ឬ

៤-ជាការបង្ខំឱ្យជនរងគ្រោះធ្វើពេស្យាចារនៅក្រៅប្រទេស ឬបង្ខំជនរងគ្រោះដែលជាបរទេសឱ្យធ្វើពេស្យាចារនៅលើទឹកដីកម្ពុជា ។

តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និង



# ច្បាប់
## ស្តីពី
## ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅបង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីធ្វើនីតិសម្បទានិងលើកកំពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្តីថ្លៃថ្នូររបស់មនុស្សនិងការការពារសុខភាពនិងសុខុមាលភាពរបស់ប្រជាជន ។

មាត្រា ២.-

ត្រូវហាមឃាត់ដាច់ខាតអំពើពង្រត់មនុស្សយកទៅលក់ដូរ ឬយកទៅធ្វើពេស្យាចារនិងអំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុងឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## អំពីអំពើពង្រត់មនុស្សយកទៅលក់ ឬយកទៅធ្វើពេស្យាចារ

**មាត្រា ៣.-**

ជនណាអូសទាញមនុស្ស ទោះបីស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាសឬគ្រឿងអលង្ការឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែងឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជន អាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញឬទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ឬផ្តល់មធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តបទល្មើស ។



ហាមស្នាក់អាស្រ័យមកផ្តន្ទាបន្ថែមពីលើមូលទោសខាងលើនេះបាន ។

**មាត្រា ៦.-**

អ្នកសបគំនិតឬអ្នកប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤ និង ៥ ត្រូវទទួលទោសដូចអ្នកប្រព្រឹត្តដែរ ។

## ជំពូកទី ៤
## អំពើអនាចារ

**មាត្រា ៧.-**

ជនណាដែលបើកកន្លែងសម្រាប់ប្រព្រឹត្តអំពើអនាចារឬអំពើអាសអាភាសផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១ឆ្នាំ ដល់ ៥ឆ្នាំ** និងពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ " **ប្រាំលានរៀល** " ដល់ ៣០.០០០.០០០៛០០ "សាមសិបលានរៀល" ។ **ក្នុងករណីមិនរាងចាល** ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

មាត្រា ៨.-

ជនណាដែលបានប្រព្រឹត្តអំពើរនាចារ លើអនីតិជនអាយុក្រោម ១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្តី ឬដោយទិញក្មេងនោះពីអ្នកដទៃក្តី ឬទិញពីជនជាមេពេស្យាក្តី ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវយកអតិបរមានៃទោសមកអនុវត្ត ។

តុលាការអាចយកអនុទោសគ្រប់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្តន្ទាបន្ថែមលើបូលទោសខាងលើនេះបាន ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ៩.-

ការណែនាំលំអិតសម្រាប់អនុវត្តច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១០.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។



ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ចែម ស្គួន